**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**

លេខ: ០៣៧៨ ឧ.អធ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ដំណើរឡើងវិញ នៅតាមការដ្ឋានរ៉ែថ្មសំណង់

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង ពង្រឹងការគ្រប់គ្រងការប្រមូលចំណូលសួយសារធនធានរ៉ែពីផលិតកម្មរ៉ែថ្មសំណង់ ដែលដំណើរការក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានរ៉ែថ្ម ឱ្យប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom PenhTel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពផលិតកម្ម អាជីវកម្ម ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែថ្មសំណង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

សម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ការធ្វើអាជីវកម្មរ៉ែថ្មសំណង់(ហៅកាត់ថាសម្បទានិក)ទាំងអស់ ត្រូវបំពាក់ជញ្ជីងថ្លឹងយានយន្តដឹកផលិតផលថ្មសំណង់(ហៅកាត់ថាជញ្ជីងថ្លឹង) នៅតាមការដ្ឋានរបស់ខ្លួន ស្របតាមនីតិវិធី និងលក្ខខណ្ឌកំណត់ក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤.-**

ជញ្ជីងថ្លឹងត្រូវដាក់នៅតាមច្រកចេញដែលតម្រូវឱ្យមានតែមួយគត់ នៅតាមការដ្ឋានរ៉ែថ្មសំណង់នីមួយៗ។ គ្រប់យានយន្តដឹកជញ្ជូនផលិតផលថ្មសំណង់ទាំងអស់ត្រូវចេញតាមច្រកដែលមានដាក់ជញ្ជីងថ្លឹង។

ការដឹកជញ្ជូនផលិតផលថ្មសំណង់ចេញពីការដ្ឋានរ៉ែ ដោយមិនឆ្លងកាត់ជញ្ជីងថ្លឹង នឹងត្រូវចាត់ទុកថាល្មើសនឹងមាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ ៥.-**

ជញ្ជីងថ្លឹងត្រូវបំពាក់ភ្ជាប់នឹងម៉ាស៊ីនកុំព្យូទ័រដែលមានកម្មវិធីកត់ត្រាទុកនូវបរិមាណថ្មដែលបានដឹកចេញគ្រប់ជើងនីមួយៗ។

ជញ្ជីងថ្លឹងត្រូវមានការធានានូវភាពសុក្រឹតដោយមានការបញ្ជាក់ពីអ្នកផ្គត់ផ្គង់ជញ្ជីងថ្លឹងនោះ។

**ប្រការ ៦.-**

ក្នុងករណីដែលជញ្ជីងថ្លឹង ឬម៉ាស៊ីនកុំព្យូទ័រ ឬកម្មវិធីកត់ត្រាទិន្នន័យ មិនអាចដំណើរការបានដោយសារបញ្ហាបច្ចេកទេសណាមួយ ដែលមិនអាចជួសជុលឱ្យដំណើរការបានភ្លាមៗ សម្បទានិកត្រូវជូនដំណឹងជាបន្ទាន់មកមន្ទីររ៉ែ និងថាមពលដែលទីតាំងការដ្ឋាននោះស្ថិតនៅ ហើយត្រូវផ្អាកដំណើរការដឹកជញ្ជូនជាបណ្តោះអាសន្ន។

មន្ទីររ៉ែ និងថាមពលត្រូវចាត់មន្ត្រីជំនាញឱ្យចុះទៅកាន់ការដ្ឋាននោះជាបន្ទាន់ ដើម្បីត្រួតពិនិត្យការផ្អាកសកម្មភាពដឹកជញ្ជូន។

**ប្រការ ៧.-**

ក្នុងករណីដែលជញ្ជីងថ្លឹង ឬម៉ាស៊ីនកុំព្យូទ័រ ឬកម្មវិធីកត់ត្រាទិន្នន័យមិនអាចជួសជុលដាក់ឱ្យដំណើរការវិញបាន សម្បទានិកអាចស្នើសុំមន្ត្រីមន្ទីររ៉ែ និងថាមពលឱ្យនៅប្រចាំការ ដើម្បីកត់ត្រាការដឹកជញ្ជូន។ មន្ត្រីមន្ទីររ៉ែ និងថាមពលដែលនៅប្រចាំការត្រូវធ្វើការកត់ត្រាឱ្យបានច្បាស់លាស់នូវចំនួនយានយន្តដែលបានដឹកចេញ បរិមាណថ្មសំណង់ និងពេលវេលានៃការដឹកចេញ ហើយត្រូវធ្វើរបាយការណ៍ជូនមកមន្ទីរជារៀងរាល់ថ្ងៃ។

យ៉ាងណាក៏ដោយការជួសជុលជញ្ជីងថ្លឹង ឬម៉ាស៊ីនកុំព្យូទ័រ ឬកម្មវិធីកត់ត្រាទិន្នន័យ មិនអនុញ្ញាតឱ្យហួសពីរយៈពេល១០(ដប់)ថ្ងៃឡើយ។ ផុតរយៈពេលនេះ ការដឹកជញ្ជូនផលិតផលថ្មសំណង់ត្រូវផ្អាករហូតទាល់តែបញ្ហាបច្ចេកទេសដែលបានកើតឡើង ត្រូវបានជួសជុលឱ្យដំណើរការវិញបានជាប្រក្រតីដូចដើម។

មន្ត្រីជំនាញនៃមន្ទីររ៉ែ និងថាមពលត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ហើយត្រូវចុះហត្ថលេខាលើការបញ្ជាឱ្យដាក់ដំណើរការជញ្ជីងថ្លឹងឡើងវិញ នៅពេលបញ្ហាបច្ចេកទេសត្រូវបានជួសជុលរួច។

**ប្រការ ៨.-**

សម្បទានិកត្រូវរក្សាទុកទិន្នន័យបរិមាណផលិតផលថ្មសំណង់ ដែលបានកត់ត្រាទុកនេះឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងរយៈពេល០៥(ប្រាំ)ឆ្នាំ គិតពីកាលបរិច្ឆេទដែលបានលក់ផលិតផលថ្មសំណង់។

ការរក្សាទុកទិន្នន័យក្នុងកថាខណ្ឌខាងលើនេះ ជាកាតព្វកិច្ចបន្ថែមទៅលើកាតព្វកិច្ចក្នុងការរក្សា និងតម្កល់ទុកឯកសារ និងទិន្នន័យដូចមានចែងក្នុងប្រកាសលេខ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែដោយសម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់។

**ប្រការ ៩.-**

សម្បទានិកត្រូវផ្តល់នូវទិន្នន័យបរិមាណផលិតផលថ្មសំណង់ដែលបានកត់ត្រាទុក ដោយម៉ាស៊ីនកុំព្យូទ័រ តាមការតម្រូវរបស់ក្រសួង ដោយក្រសួងអាចតម្រូវឱ្យបញ្ជូនទិន្នន័យតាមប្រព័ន្ធអ៊ីនធើណែតមកក្រសួងជាប្រចាំ ឬតាមរយៈពេលកំណត់ណាមួយ។

**ប្រការ ១០.-**

សម្បទានិកដែលមិនទាន់មានជញ្ជីងថ្លឹង ត្រូវធ្វើការដាក់ជញ្ជីងថ្លឹងក្នុងរយៈពេល០៦(ប្រាំមួយ) ខែគិតចាប់ពីថ្ងៃចុះហត្ថលេខាលើប្រកាសនេះ។ ផុតរយៈពេលនេះ ការដឹកជញ្ជូនផលិតផលថ្មសំណង់ចេញពីការដ្ឋានត្រូវផ្អាកជាបណ្ដោះអាសន្ន រហូតទាល់តែជញ្ជីងថ្លឹងត្រូវបានបំពាក់និងដាក់ឱ្យដំណើរការ។

**ប្រការ ១១.-**

ការស្នើសុំអាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ការធ្វើអាជីវកម្មរ៉ែថ្មសំណង់ ត្រូវបញ្ចូលការដាក់ជញ្ជីងថ្លឹងជាផ្នែកមួយនៃឧបករណ៍ សម្ភារក្នុងផលិតកម្មរបស់ខ្លួន។

គ្មានការធ្វើអាជីវកម្មរ៉ែថ្មសំណង់ណាមួយត្រូវបានអនុញ្ញាតឱ្យដំណើរការ ដោយគ្មានការដាក់ជញ្ជីងថ្លឹងឡើយ។

**ប្រការ ១២.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានធនធានរ៉ែ និងប្រធានមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ស៊ុយ សែម

**<u>កន្លែងទទួល</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាលារាជធានី-ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ